00757949

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 12 / 2011
ម៉ោង (Time/Heure) : 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E149

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

**សាធារណៈ / Public**

កាលបរិច្ឆេទ: ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សមត្ថកិច្ចផ្តាច់មុខរបស់អង្គជំនុំជម្រះសាលាដំបូងលើបុគ្គលទាំងអស់ដែលត្រូវកោះហៅមកបង្ហាញខ្លួននៅសវនាការ និងការមើលថែទាំបុគ្គលទាំងនោះមុនពេល និងអំឡុងពេលពួកគេផ្តល់សក្ខីកម្ម

ដើម្បីជាប្រយោជន៍ដល់ភាគី អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់បំភ្លឺទៅភាគីថាបញ្ហាពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងគឺស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់អង្គជំនុំជម្រះនៅមុនពេល និងអំឡុងពេលនៃការធ្វើសក្ខីកម្មនេះ។

ក្នុងករណីមានការលើកឡើងអំពីបញ្ហាវេជ្ជសាស្ត្រណាមួយ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាបុគ្គលណាម្នាក់នឹងត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ អង្គជំនុំជម្រះសាលាដំបូងនឹងអនុវត្តតាមការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ក្រោមការសម្របសម្រួលដោយអង្គភាព

គាំពារសាក្សី និងអ្នកជំនាញ។ ភាគីពុំអាចសម្រេចដោយឯកតោភាគីបានឡើយថាសាក្សីណាម្នាក់ដែលអង្គជំនុំជម្រះបានកោះហៅគួរត្រូវបង្ហាញខ្លួនដែរ ឬយ៉ាងណានោះ ដោយហេតុថាមានតែអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះដែលមានសិទ្ធិសម្រេចលើបញ្ហានេះ។

ដើម្បីសម្របសម្រួលការវាយតម្លៃខាងលើ និងដើម្បីធានាបានថាបុគ្គលទាំងអស់ដែលត្រូវបង្ហាញខ្លួនចំពោះមុខ អ.វ.ត.ក បានទទួលជំនួយគាំទ្រឲ្យបានច្រើនតាមដែលអាចធ្វើទៅបានតាមការចាំបាច់នោះ អង្គជំនុំជម្រះសូមបញ្ជាក់ទៀតថាអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជាអ្នកទទួលបន្ទុកចំពោះការធ្វើដំណើររបស់បុគ្គលទាំងអស់ដែលអង្គជំនុំជម្រះកោះហៅ និងកិច្ចការថែទាំពួកគេនៅភ្នំពេញនៅមុនពេល និង អំឡុងពេលបុគ្គលទាំងអស់នោះធ្វើសក្ខីកម្ម និងកិច្ចការគាំទ្រសុខមាលភាព និងពស្តុភារពាក់ព័ន្ធផ្សេងៗទៀត។

កិច្ចការនេះពុំប៉ះពាល់ឡើយដល់សិទ្ធិរបស់សហមេធាវីនាំមុខ ឬមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជួបកូនក្តីរបស់ខ្លួនដើម្បីធ្វើកិច្ចការច្បាប់តាមការចាំបាច់ មុនពេលពួកគេផ្តល់សក្ខីកម្ម ក្នុងពេលដែលពួកគេស្នាក់នៅទីក្រុងភ្នំពេញ។ សហមេធាវីនាំមុខ ឬមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគួរសហការជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញដើម្បីសម្របសម្រួលកិច្ចការនេះតាមការជាក់ស្តែង។